TAKE CHARGE CALIFORNIA!

ការដឹងពីសិទ្ធិរបស់អតិថិជនរបស់អ្នក ផ្តល់ឱ្យអ្នកនូវ អានុភាពបន្ថែមនៅក្នុងផ្សារ! វាកំណត់ជាឱ្យអ្នក:

- ការពារខ្លួនអ្នក និងក្រុមគ្រួសាររបស់អ្នក។
- ទទួលបានផលច្រើនបំផុតពីប្រាក់កាសរបស់អ្នក។
- ជួយដល់សហគមន៍របស់អ្នក តាមរយៈការចែករំលែកចំនេះដឹង។
- ការពារបរិស្ថាន។

វាមានការងាយស្រួលក្នុងការធ្វើទំនួលខុសត្រូវ-យើងអាចបង្ហាញអ្នកបាន! សូមទូរស័ព្ទមកលេខ

800-952-5210

រឺបើកមើលវិបសាយ

WWW.TAKECHARGECA.CA.GOV

ត្រូវឆ្លៀសវៃ។ ដឹងពីសិទ្ធិរបស់អតិថិជនរបស់អ្នក។ សួរសំនួរមុននឹងទិញ។ ទាមទាររកការប្រមាណតម្លៃ ជាលាយលក្ខណ៍អក្សរ។ អានកិច្ចសន្យា មិនត្រូវចេះតែចុះហត្ថលេខាទេ។ ធ្វើការស្រាវជ្រាវ។ សុំមើលអាជ្ញាប័ណ្ណ វិជ្ជាជីវៈ មុននឹងជួលបុគ្គលនោះ។

ប្រកបដោយសុវត្ថិភាព។ ការពារប្រាក់កាសរបស់អ្នក ត្រូវធ្វើការវិនិយោគដោយឆ្លៀសវៃ។ ប្រៀបធៀប តម្លៃ សិក្សាពីគោលការណ៍នៃការបញ្ជូនត្រឡប់ និងពិនិត្យ មើលការធានាផលិតផល។ ពិនិត្យបញ្ជាក់អាជ្ញាប័ណ្ណ មុននឹងជួលនរណាម្នាក់។ ដឹងពីវិធីចៀសវាងការកែងបន្លំ។ ការពារអត្តសញ្ញាណរបស់អ្នកពីជនកែងបន្លំ។ ពិនិត្យមើលមូលនិធិសប្បុរសធម៌ មុននឹងធ្វើការបរិច្ចាគ។

ត្រូវសង្កេត។ សម្លេងរបស់របស់អ្នកពោរពេញទៅ ដោយអានុភាព! ការសាកសួរមុននឹងទិញ ធ្វើឱ្យអ្នកលក់ និងអ្នកមានជំនាញទាំងឡាយដឹងថា អ្នកបានទទួលដំណឹងអំពីទំនិញរឺសេវាកម្ម នោះ និងពោរពេញដោយ ទំនុកចិត្ត ។ ការជជែកគ្នាពីដំបូងអំពីការរំពឹងទុករបស់អ្នក អាចជួយឱ្យជៀសផុតពីជម្លោះនៅពេលក្រោយ។ ការដឹងពី របៀបបង្ហឹតវ៉ាអាចជួយអ្នកដោះស្រាយជម្លោះ នៅពេល ដែលមានរឿងកើតឡើងមិនដូចអ្វីដែលគួរកើត។